Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយភ្លាមៗ

# គម្រោងរបស់និស្សិត បង្ហាញពីនវានុវត្តន៍ក្នុងការតាមដានទន្លេមេគង្គ

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣** – គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) បានប្រកាសលទ្ធផលអ្នកឈ្នះ ក្នុងកម្មវិធីប្រកួតប្រជែងផ្នែកបច្ចេកវិទ្យាតាមដានទន្លេលើកដំបូងបង្អស់ សម្រាប់និស្សិតសាកលវិទ្យាល័យ ដែលជាផ្នែកមួយនៃកិច្ចប្រឹងប្រែងកាន់តែទូលំទូលាយ ក្នុងការបន្តស្វែងរកបច្ចេកវិទ្យាទំនើបៗ ជួយគាំពារដល់ទន្លេដែលធំជាងគេបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍ និងស្របពេលជាមួយគ្នាផងដែរ ដើម្បីជំរុញការបង្កើតបច្ចេកវិទ្យានៅក្នុងតំបន់។

ដូចដែលបុគ្គលខ្លះបានលើកឡើងថា “ដំណោះស្រាយទន្លេមេគង្គ សម្រាប់បញ្ហាប្រឈម ទន្លេមេគង្គ”។ ហេតុដូច្នេះ នាពេលថ្មីៗនេះ MRC បានសម្រេចគោលដៅនេះ តាមរយៈព្រឹត្តិការណ៍ដ៏ពិសេសមួយ ដែលមានក្រុមនិស្សិតមកពីប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ចូលរួមប្រកួតប្រជែងអភិវឌ្ឍបច្ចេកវិទ្យាឧបករណ៍ចាប់សញ្ញាទូរមាត្រ ដែលអាចវាស់ស្ទង់ និងតាមដានកម្រិតទឹក បរិមាណភ្លៀងធ្លាក់ សំណើមដី ឬគុណភាពទឹក។

កម្មវិធីនេះជាកម្មវិធីលេចធ្លោមួយក្នុងកិច្ចប្រជុំកំពូល MRC លើកទី៤។ គណៈវិនិច្ឆ័យអន្តរជាតិមួយក្រុមបានផ្តល់រង្វាន់ធំបំផុតនូវទឹកប្រាក់ចំនួន៥.០០០ ដុល្លារអាមេរិក ដល់ក្រុមឈ្នះនីមួយៗ សម្រាប់ក្រុមទាំងបួនដោយឡែកពីគ្នា ក្នុងនោះ ក្រុមចំនួនបីមកពីសាកលវិទ្យាល័យនៃប្រទេសកម្ពុជា និងមួយក្រុមពីប្រទេសឡាវ។ បន្ថែមពីនេះ ទឹកប្រាក់ចំនួន១.០០០ ដុល្លារអាមេរិក ក៏បានផ្តល់ជូនដល់ក្រុមចំណាត់ថ្នាក់កិត្តិយសទាំងបួនក្រុមផងដែរ។

នៅក្នុងកម្មវិធីផ្តល់រង្វាន់នៅទីក្រុងវៀងចន្ទ អ្នករៀបចំកម្មវិធីរបស់ MRC បានកោតសរសើរដល់ក្រុមទាំងអស់ដែលបានចូលរួមនៅវគ្គចុងក្រោយថាជា “បុគ្គលគំរូ” សម្រាប់មិត្តភ័ក្តិរបស់គេ ដោយហេតុថា គោលបំណងរបស់ការប្រកួតនេះ មានលក្ខណៈទាំងការអនុវត្តជាក់ស្តែង និងជានិមិត្តរូប។ ជាការពិតណាស់ លោក សានទិ បារាន (Santi Baran) ប្រធានផ្នែកយុទ្ធសាស្ត្រ និងភាពជាដៃគូរបស់ MRC បានលើកឡើងថាពួកគេបានរួមវិភាគទានដ៏មានតម្លៃចំពោះសង្គមក្នុងតំបន់ទន្លេមេគង្គ។ ទន្លេមេនៃទន្លេមេគង្គ និងដៃទន្លេនេះ ខ្វះឧបករណ៍ចាប់សញ្ញាឲ្យបានគ្រប់គ្រាន់ នៅតាមផ្នែកខ្លះៗ ខណៈឯផ្នែកខ្លះទៀត វាពឹងផ្អែកខ្លាំងលើឧបករណ៍ដែលមានតម្លៃថ្លៃខ្លាំង ក្នុងការថែទាំ។

លោក បារាន បានប្រាប់អ្នកចូលរួមកថា “នៅពេលយើងចាប់ផ្តើមដំណើរការកម្មវិធីនេះ ជាលើកដំបូង យើងមានការគិតគូរក្នុងចិត្តមួយ នោះគឺវិធីកាត់បន្ថយការចំណាយលើការតាមដាន។ ប្រសិនបើយើងនៅតែអនុ

វត្តការតាមដាននេះ យើងត្រូវតែចាប់ផ្តើមធ្វើការបង្កើតឡើងវិញ និងទទួលយកការផ្លាស់ប្តូរ។ ហើយការផ្លាស់ប្តូរនេះ មកជាមួយនឹងនវានុវត្តន៍”។

បន្ទាប់មក លោក បារាន បាននិយាយទៅកាន់និស្សិតដោយផ្ទាល់ថា “យើងបានដឹងថា វាត្រូវតែជាយុវជនដែលគួរផ្តល់ឱកាសក្នុងការច្នៃប្រឌិតនានាដល់ពួកគេ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរពួ។ ហើយនឹងគ្មាននរណាម្នាក់ អាចធ្វើកិច្ចការនេះបានល្អប្រសើរជាងយុវជនដែលនៅទីនេះ នាពេលនេះទេ។ អ្នកទាំងអស់គ្នាបានបង្ហាញថា ប្រជាជនទន្លេមេគង្គ អាចផលិតបច្ចេកវិទ្យាទាំងនេះបានដោយខ្លួនឯង នៅទីនេះ នៅលើទឹកដីទន្លេមេគង្គ”។

នៅក្នុងផ្នែកវាស់ស្ទង់ និងតាមដានកម្រិតទឹក ចំណាត់ថ្នាក់ទី១ បានទៅបណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ខណៈដែលសាកលវិទ្យាល័យធុយល័យវៀតណាម ទទួលបានចំណាត់ថ្នាក់កិត្តិយស, សម្រាប់ផ្នែកគុណភាពទឹក ចំណាត់ថ្នាក់ទី១ បានទៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ដោយសាកលវិទ្យាល័យជាតិឡាវ ទទួលបានចំណាត់ថ្នាក់កិត្តិយស, រីឯផ្នែកភ្លៀងធ្លាក់វិញ ចំណាត់ថ្នាក់ទី១ បានទៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដោយវិទ្យាស្ថានបច្ចេកវិទ្យាស៊ូតសាកាប្រទេសឡាវ ទទួលបានចំណាត់ថ្នាក់កិត្តិយស, ហើយនៅក្នុងផ្នែកសំណើមដី ចំណាត់ថ្នាក់ទី១ បានទៅសាកលវិទ្យាល័យជាតិឡាវ ដោយសាកលវិទ្យាល័យកាន់ធើប្រទេសវៀតណាម ទទួលបានចំណាត់ថ្នាក់កិត្តិយស។

និស្សិតកម្ពុជាម្នាក់ មកពីក្រុមឈ្នះ បានពណ៌នាថា ការប្រកួតនេះ គឺជាបទពិសោធន៍ដ៏អស្ចារ្យមួយ។ សូលិតា ប៉ុន មកពីបណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា បានលើកឡើងថា “បន្ទាប់ពីចូលរួមការប្រកួតនេះ យើងបានដឹងថា គ្មាននរណាម្នាក់អាចជួយយើងបានទេ បើយើងមិនជួយខ្លួនឯង។ ការប្រកួតនេះ គឺជាឱកាសដ៏ល្អមួយសម្រាប់ឲ្យយុវជនទន្លេមេគង្គ ឈានឆ្ពោះទៅមុខ និងចូលរួមរកវិធីដោះស្រាយបញ្ហាប្រឈម ដែលទន្លេមេគង្គជួបប្រទះ។ វាផ្តល់ឱកាសឲ្យយើងបង្ហាញពីគំនិតបែបនវានុវត្តន៍ ក៏ដូចជាអារម្មណ៍របស់យើងផងដែរ ថាយើងមិនត្រឹមតែខ្វល់ពីទន្លេនេះទេ តែយើងក៏បារម្ភពីពិភពលោកនេះផងដែរ”។

ការប្រកួតនេះ បានចាប់ផ្តើមក្នុងនាមជាមធ្យោបាយមួយ ដើម្បីអភិវឌ្ឍឧបករណ៍ទំនើប មានប្រសិទ្ធភាពចំណាយ និងមានចីរភាព ដែលអាចក្លាយជាជម្រើសអនុវត្តជាក់ស្តែងសម្រាប់បច្ចេកវិទ្យាតាមដានទន្លេដែល MRC បានប្រើប្រាស់ថែទាំតាមទន្លេមេគង្គ និងដៃទន្លេនេះ។ ស្ថានីយប្រមាណ២៥០ ធ្វើការតាមដានផ្នែកផ្សេងៗ ដូចជាជលសាស្រ្ត ភ្លៀងធ្លាក់ គុណភាពទឹក សុខភាពអេកូឡូស៊ី ជលផល និងគ្រោះរាំងស្ងួត។ ប៉ុន្តែ ឧបករណ៍ទាំងនេះ ជាទូទៅត្រូវបានផលិតនៅបរទេស មានតម្លៃថ្លៃ និងពិបាកក្នុងការថែទាំ។

ជាមួយនឹងគោលគំនិតនេះ MRC បានចាប់ផ្តើមការប្រកួតជាផ្លូវការ នៅដើមខែតុលា ដោយមានក្រុមមកពីសាកលវិទ្យាលជ្រើសរើសជាមុនចំនួន១៥ ក្នុងបណ្តាលប្រទេសទន្លេមេគង្គ ធ្វើការក្រោមការដឹកនាំរបស់សាស្រ្តាចារ្យពួកគេ ក្នុងនាមជាសាស្រ្តាចារ្យណែនាំ។ គម្រោងដែលជោគជ័យបំផុត ក៏បានទទួលជំនួយថវិកាតិចតួច ចំនួន៨០០ ដុល្លារអាមេរិក ដើម្បីអភិវឌ្ឍគោលគំនិតរបស់គេ។

ដោយសារបច្ចេកវិទ្យាចាប់សញ្ញា ជាទូទៅត្រូវបានតំឡើងតាមច្រាំងទន្លេ ឬក្នុងតំបន់កសិកម្ម គោលបំណងសម្រាប់និស្សិត គឺត្រូវរៀបចំបង្កើតបច្ចេកវិទ្យាឲ្យសមស្របទៅនឹងសណ្ឋានដី ទីតាំង អាកាសធាតុ និងមុខងារនានា អាចប្រតិបត្តិការបានតាមថាមពលអគ្គិសនី និងមានសមត្ថភាពប្រមូល និងបញ្ជូនទិន្នន័យទូរមាត្រពីស្ថានីយ ទៅកាន់ម៉ាស៊ីនមេ ទៅតាមពេលវេលាជាក់ស្តែង។

បន្ទាប់មក និស្សិតវគ្គចុងក្រោយ ត្រូវបានប្រមូលផ្តុំនៅស្នាក់ការកណ្តាល MRC ក្នុងទីក្រុងវៀងចន្ទ ដើម្បីធ្វើការបង្ហាញពីគម្រោងរបស់ពួកគេ នាថ្ងៃទី៣០ និង៣១ មិនា ទៅកាន់គណៈវិនិច្ឆ័យអន្តរជាតិមួយក្រុម ដែលមានអព្យាក្រិត។ គណៈវិនិច្ឆ័យ បានធ្វើការវាយតម្លៃលើគម្រោងទាំងនេះ ទៅតាមសុក្រិតភាព ភាពធន់ ប្រសិទ្ធភាពចំណាយ និងនវានុវត្តភាព។

នៅក្នុងការវាយតម្លៃគម្រោងទាំងនេះ គណៈវិនិច្ឆ័យ បានលើកឡើងដែរថា ពួកគេ ក៏មានអារម្មណ៍ភ្ញាក់ផ្អើលខ្លាំង ដោយសារភាពចម្រុះនៅក្នុងក្រុមផងដែរ ទាំងផ្នែកភេទ និងមុខជំនាញ។ ក្នុងចំណោមនិស្សិតបរិញ្ញាបត្រទាំង៧០ នាក់ មានស្ត្រីចំនួន៣៤ នាក់ និងបុរស៣៦ នាក់។ ឧបករណ៍ចាប់សញ្ញាផ្សេងៗគ្នាទាំង១០ ត្រូវបានបង្កើតឡើង និងធ្វើតេស្តសាកល្បងដោយនិស្សិតមកពីជំនាញផ្សេងៗ រួមមានរូបវិទ្យា គណិតវិទ្យា ជលសាស្ត្រ គីមីវិទ្យា ហ្គេម បច្ចេកទេសព័ត៌មាន ជីវវិទ្យា វិទ្យាសាស្ត្របរិស្ថាន មហាសមុទ្រ និងឧត្តុនិយម។

បណ្ឌិត វ៉េន រូប៊ីនសុន (Wayne Robinson) អ្នកស្រាវជ្រាវជាន់ខ្ពស់នៅសាកលវិទ្យាល័យឆាលស្ទើតនៃប្រទេសអូស្ត្រាលី និងជាគណៈវិនិច្ឆ័យមួយរូបក្នុងចំណោមគណៈវិនិច្ឆ័យទាំងបី បានលើកឡើងថា “ពួកគេបានធ្វើការនៅក្នុងក្រុមជំនាញចម្រុះ និងបានធ្វើបទបង្ហាញនៅក្នុងស្តង់ដារខ្ពស់បំផុត។ បទបង្ហាញទាំងនោះ ត្រូវបានធ្វើឡើងជាភាសាបរទេស។ វាមិនមានអ្វីដែលធ្វើឲ្យគណៈវិនិច្ឆ័យ ចាប់អារម្មណ៍លើសពីនេះទៀតទេ”។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**
គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក មាស សុកក្រ្ក មន្រ្តីជំនាញផ្នែកភាគីពាក់ព័ន្ធ

មន្ត្រីសារព័ត៌មានបណ្ដោះអាសន្ន, លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរស័ព្ទដៃ៖ +៨៥៦-២០-៧៧៧៧៩១៦៨

###